# បុណ្យដារលាន និងទំនៀមខ្លះនៅក្នុងរដូវប្រមូលផលស្រូវ

ទំនៀមក្នុងសង្គមខ្មែរពាក់ព័ន្ធនឹងការធ្វើស្រែ ឬពាក់ព័ន្ធ "ស្រូវ" មានច្រើនណាស់ រាប់តាំងពីច្រត់ព្រះនង្គ័ល សុំទឹកភ្លៀង សំពះព្រះខែ អកអំបុក ទានភ្លើង ឬុងក្រឡាន សយវេរ ពូនភ្នំស្រូវ ហៅព្រលឹងស្រូវ ឬដុតភ្នំស្រូវ[1] ហើយពិធីខ្លះក៏ប្រារព្ធក្នុងសហគមន៍ជនជាតិដើមភាគតិច ឬនៅតំបន់អង្គរមានប្រារព្ធពិធីដែលអ្នកស្រុកហៅថា "ឡើងមាឃ"។ ចំពោះ "ដារលាន" ជាទំនៀមប្រពៃណី ដែលអ្នកស្រាវជ្រាវយល់ថាក៏មានអត្ថន័យពាក់ព័ន្ធការធ្វើកសិកម្ម ផ្សារភ្ជាប់នឹងព្រះពុទ្ធសាសនា។ អ្នកស្រុកហៅទំនៀមនេះដោយឈ្មោះទីទៃពីគ្នាតាមតំបន់ដូចជា បុណ្យបោសលាន បុណ្យកណ្ដាលភូមិ ឬដារភូមិ បុណ្យដារបាតលាន ឬបុណ្យពូនភ្នំស្រូវ។ ជាទូទៅគេតែងប្រារព្ធធ្វើក្រោយប្រមូលផល ពោលគឺក្រោយច្រូតកាត់រួចរាល់។ បើក្នុងឯកសារព្រះរាជពិធីទ្វាទសមាស មាននិយាយព្រះរាជពិធីពីរពាក់ព័ន្ធ "ស្រូវ" ប្រារព្ធក្នុងខែមាឃ គឺ "ព្រះរាជពិធីពូនភ្នំស្រូវ" និង "ព្រះរាជកុសលមាឃបូជា"។[2] ទន្ទឹមនេះ ក្នុងកាលកន្លងមករាជរដ្ឋាភិបាលក៏ធ្លាប់រៀបចំដារលានឲ្យទៅជាចំណែកមួយនៃយន្តការលើកស្ទួយស្រូវអង្ករក្នុងវិស័យកសិកម្មដែរ (រូបលេខ១-២)។






រូបលេខ១ កម្រងឯកសារស្ដីពីបុណ្យដារលាន រៀបចំចងក្រងដោយក្រសួងកសិកម្ម ឆ្នាំ២០០៨

រូបលេខ២ ឯកឧត្តម ហ៊ុន ម៉ានី អញ្ជើញជាអធិបតីក្នុងពិធីបុណ្យដារលានប្រពៃណីកសិករនៅស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ឆ្នាំ២០២២ (រូបថត៖ វិមាន៧មករា)

---

[1] សូមអាន៖ ភិន សំណាង, ២០១១ និង ពេជ្រ សល់, ១៩៦៦, ទំ.៨២-៨៨

[2] ចាប ពិន, ១៩៦៩, ទំ.១៤៥-១៥៦

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

## អត្ថបទ៖ បុណ្យដារលាន និងទំនៀមខ្លះនៅក្នុងរដូវប្រមូលផលស្រូវ

ចំពោះប្រវត្តិដារលាន ពុទ្ធសាសនិកខ្លះបានពន្យល់ភ្ជាប់សាច់រឿងព្រះចុល្លកាល និងមហាកាល ដែលជាកសិករ។ និទាននោះលើកឡើងថា ថ្ងៃមួយចុល្លកាល(ប្អូន)បានដកដង្ហើមស្រូវសាលីទំពារ យល់ថាមានរសជាតិឆ្ងាញ់ពិសាក៏បបួលមហាកាល(បង)យកស្រូវនោះធ្វើទាន តែបងមិនព្រម ហើយបង្ខំចិត្តចែកស្រែឲ្យប្អូនយកទៅធ្វើអ្វីតាមចិត្តចង់ទៅ។ ចុល្លកាលសប្បាយរីករាយណាស់ដោយគិតថា ខ្លួននឹងបានធ្វើទានដ៏ប្រសើរមុនគេ ក៏យកស្រូវទាំងនៅខ្ចីកិនលាយទឹកដោះស្រស់ ទឹកឃ្មុំ និងស្ករ ទៅថ្វាយព្រះពុទ្ធអង្គនិងភិក្ខុសង្ឃ។ បន្ទាប់ពីធ្វើទានរួច ចុល្លកាលត្រឡប់ទៅមើលស្រូវរបស់ខ្លួន ស្រាប់តែឃើញចម្រើនបានផលដូចគេចង់ ឥតខូចខាតឡើយ គឺហាក់ដូចជាបុណ្យបានឲ្យផលជាក់ស្ដែង។ ដោយឃើញអានិសង្សដូច្នេះ ចុល្លកាលក៏តាំងចិត្តធ្វើទានបន្តទៀតក្នុងរដូវធ្វើស្រែឥតបីខាន។[3] ប្រហែលមានហេតុក្នុងរឿងខាងលើជាមូលដ្ឋាន ទើបគេសង្កេតឃើញដារលាន តែងមានកិច្ចភ្ជាប់នឹងព្រះពុទ្ធសាសនាជាធម្មតា។ បើនៅឯតំបន់អង្គរ អ្នកស្រុកតែងរៀបចំដារលាន ឬបុណ្យពូនភ្នំស្រូវ ឬខ្លះហៅថា "ឡើងមាឃ" យ៉ាងហ្មត់ចត់ ពោលគឺរាប់តាំងពីរោងពិធី គ្រឿងរណ្ដាប់ និងកិច្ចផ្សេងៗ ដែលរាប់ត្រួសៗមានដូចជា រានហៅព្រលឹងស្រូវ រានយមរាជ រានពុទ្ធគុណ កិច្ចក្រុងពាលី កិច្ចបួងសួងភ្នំស្រូវ ហៅព្រលឹងស្រូវ និងជញ្ជាត់ព្រលឹងស្រូវ (រូបលេខ៣-៤)។[4]



រូបលេខ៣-៤ ភ្នំស្រូវ និងកិច្ចហៅព្រលឹងស្រូវនៅភូមិតានី ខេត្តសៀមរាប (រូបថត៖ សុខ កែវវណ្ណារ៉ា)

---

[3] សូមស្ដាប់ធម្មទេសនាផ្សាយលើតំណ https://www.youtube.com/watch?v=Zv7nw-9j6uQ

[4] សូមអាន "ពូនភ្នំស្រូវនៅតំបន់ភ្នំបូក, អង្គរ" ដោយ អាំង ជូលាន, គង់ វីរៈ, រស់ សុខុម, ២០០៧, ទំ.២៩៣-៣០៥ និង សុខ កែវវណ្ណារ៉ា "ពិធីហៅព្រលឹងស្រូវនៅភូមិតានី (សៀមរាប)" ផ្សាយលើតំណ https://ams.com.kh/khmercivilization/detail/2411

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

តាមប្រសាសន៍ព្រឹទ្ធាចារ្យខ្លះពន្យល់ថា ពីបុរាណមុនធ្វើដារលានចាស់ៗត្រូវរៀបចំទីតាំងសមរម្យមួយកន្លែង ដោយភាគច្រើនគេជ្រើសយកវាលស្រែធំណាមួយនៅកណ្ដាលភូមិសម្រាប់រៀបចំសង់រោងបុណ្យ។ កិច្ចការដំបូងនាពេលនោះ គឺត្រូវជម្រះគល់ជញ្ជ្រាំងស្រូវឱ្យរៀបស្មើ ហើយបន្ទាប់មកចាស់បុរាណនៅតំបន់ខ្លះ លោកតែងយកលាមកគោស្រស់ៗលាយជាមួយទឹកនិងដីដំបូកឱ្យជ្រាយល្មម រួចចាក់ពង្រាយលើផ្ទៃដីនោះ ដោយយករនាស់ដៃកៀរឱ្យស្មើទុកឱ្យស្ងួត ដែលដំណាក់កាលនេះលោកហៅថា "ឡើងលាន"។ គោលបំណងនៃការធ្វើបែបនេះ គឺដើម្បីឱ្យបានទីធ្លារាបស្មើធំទូលាយងាយស្រួលសម្រាប់ប្រារព្ធពិធី។ ប៉ុន្តែសម័យក្រោយៗមករហូតដល់បច្ចុប្បន្ន ប្រជាកសិករបានប្រើកន្ទេល ឬវត្ថុផ្សេងៗទៀតជាជំនួសលានលាមកគោនោះវិញ។ បច្ចុប្បន្នបើនៅតំបន់អង្គរ ខេត្តសៀមរាប ក្នុងភូមិខ្លះអ្នកស្រុកច្រើនប្រារព្ធធ្វើនៅសាលាបុណ្យប្រចាំភូមិតែម្ដង (រូបលេខ៩)។



រូបលេខ៩ កិច្ចបួងសួងក្នុងបុណ្យឡើងមាឃប្រារព្ធនៅសាលាបុណ្យភូមិបង្កោង ខេត្តសៀមរាប

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

## អត្ថបទ៖ បុណ្យដារលាន និងទំនៀមខ្លះនៅក្នុងរដូវប្រមូលផលស្រូវ

ដូចបានបញ្ជាក់ជូនខាងដើម បុណ្យដារលានតែងភ្ជាប់នឹងកិច្ចក្នុងពុទ្ធសាសនា និងកិច្ចក្នុងជំនឿជីវចល។ ដូច្នេះនៅពេលដល់វេលាកំណត់ អ្នកភូមិតែងបានជួបជុំគ្នារៀបចំគ្រឿងរណ្តាប់ផ្សេងៗសម្រាប់បូជាចំពោះព្រះរតនត្រៃ និងទីសក្ការៈក្នុងភូមិទុកជាស្រេច។ កិច្ចដំបូង អាចារ្យចាត់ចែងរៀបចំគ្រឿងពលិការបូជាបួងសួងសុំម្ចាស់ទឹកម្ចាស់ដី។ រីឯស្រូវដែលអ្នកភូមិយកមកចូលរួមពិធីទោះបីតិចឬច្រើនក្តី គេតែងរៀបចំចាក់ជាជារួមគ្នា ធ្វើជាពំនូក ឬដាក់នៅទីសមរម្យណាមួយ ដែលគេហៅថា "ភ្នំស្រូវ"។ លុះអ្នកភូមិបានចូលរួមពូនជុំគ្នាស្រេចបាច់ហើយ អាចារ្យក៏ចាប់ផ្តើមធ្វើកិច្ចបំបួសភ្នំស្រូវនោះ (រូបលេខ២៦)។ ក្នុងកិច្ចបំបួសនោះសោត គេនាំគ្នាអុជធូបដោតលើគំនរស្រូវ ដោយខ្លះបន់ស្រន់ប្រាថ្នារៀងៗខ្លួនពិសេសបួងសួងសូមឱ្យមានភ្លៀងធ្លាក់គ្រប់គ្រាន់ កោគផលស្រូវអង្ករ និងដំណាំនានាបានផលល្អប្រសើរនាឆ្នាំក្រោយទៀត។ ចូលដល់វេលាព្រលប់ តំបន់ខ្លះក៏មាននិមន្តព្រះសង្ឃសូត្រមន្ត និងសម្តែងធម្មទេសនាផងដែរ។ ព្រឹកឡើងគេនិមន្តព្រះសង្ឃឆាន់ រួចហើយទើបធ្វើកិច្ចផ្សឹកភ្នំស្រូវនោះឲ្យមកជាវត្ថុធម្មតា និងនាំគ្នាវេរប្រគេនព្រះសង្ឃយកទៅប្រើប្រាស់តាមសេចក្តីត្រូវការ។



រូបលេខ២៦ កិច្ចផ្សឹកភ្នំស្រូវ នៅភូមិបង្កោង ស្រុកប្រាសាទបាគង ខេត្តសៀមរាប

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ដោយឡែកទំនៀមពាក់ព័ន្ធនឹង "ស្រូវ" នៃរដូវប្រមូលផលនេះ គេឃើញមានការប្រារព្ធនៅទីផ្សេងទៀត ក្នុងទិដ្ឋភាពផ្សេងដែរ។ អ្នកភូមិចំណុះវត្តរុន នៃស្រុកបន្ទាយស្រី ខេត្តសៀមរាប ធ្វើកិច្ចបន្តិចបន្តួចនៅខ្ទមអ្នកតា (តាជ័យ, យាយស្រី) ស្ថិតក្នុងវត្ត។ បើតាមសង្កេតកិច្ចនៅទីនេះពុំដែលមានភ្លេង ឬកិច្ចបញ្ចូលបញ្ជាន់រូបឡើយ។ ប៉ុន្តែជាទូទៅអ្នកភូមិតែងមូលមាត់គ្នាកំណត់ធ្វើនៅថ្ងៃ៣កើត ខែមាឃ ហើយនាំយកម្ហូបចំណី ជាពិសេស "ស្រូវ" និងអង្ករ (ក្នុងនោះអ្នកខ្លះមាននំបញ្ចុក ឬអំបុក) មកដាក់សែនក្នុងខ្ទមអ្នកតា (រូបលេខ២៧)។ ចំពោះម្ហូបចំណី ពេលចប់កិច្ចសែនបីបទរួច គេយកទៅចាក់ក្បែរខ្ទមអ្នកតា។ ចំណែកស្រូវ និងអង្ករ គេទុកជាដង្វាយនៅក្នុងខ្ទមអ្នកតានោះ (រូបលេខ២៨)។[5]



រូបលេខ២៧ កិច្ចសែនព្រេនខ្ទមអ្នកតាក្នុងវត្តរុន



រូបលេខ២៨ ស្រូវ និងអង្ករ (ក្នុងថង់) ថ្វាយអ្នកតា

សរុបមក ដារលាននិងទំនៀមខ្លះក្នុងចុងរដូវប្រមូលផលស្រូវ មានច្រើនរបៀបទៅតាមភូមិស្រុក។ ប៉ុន្តែទំនៀមទាំងនោះ ក្រៅពីមានអត្ថន័យនិងខ្លឹមសារពាក់ព័ន្ធនឹងជំនឿផ្សេងៗក្នុងបរិបទទូទៅនៃសង្គមខ្មែរដែលទុកស្រូវជាព្រះមេ គឺវាស្តែងឲ្យឃើញពីការសាទរភោគផលផង និងការដឹងគុណទៅដល់អ្នកតាជាម្ចាស់ទឹកដី ជួយឲ្យភោគផលនោះបានសម្បូរហូរហៀរ។ មិនតែប៉ុណ្ណោះក្នុងជំនឿពុទ្ធសាសនិក ដារលានក៏ជាឱកាសធ្វើបុណ្យកុសល ដែលកើតពីផលស្រូវដំបូងចំពោះព្រះសង្ឃ។

[5] ក្នុងរូបលេខ២៨៖ អង្ករនិងចេកជាដង្វាយអ្នកតាពេលនោះ អ្នកភូមិអនុញ្ញាតឲ្យកុមារខ្លះខាតយកទៅផ្ទះ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារយោង

ចាប ពិន

១៩៦៩, *ព្រះរាជពិធីទ្វាទសមាស*, ភាគ៣, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

ពេជ្រ សល់

១៩៦៦, *ពិធីប្រចាំដប់ពីរខែ*, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

ភិន សំណាង

២០១១, *ស្រូវក្នុងប្រពៃណីខ្មែរ*, នគរវត្ត, ភ្នំពេញ

សុខ កែវវណ្ណារ៉ា,

២០២១, ពិធីហៅព្រលឹងស្រូវនៅភូមិតានី (សៀមរាប)" ផ្សាយលើគំណ

https://ams.com.kh/khmercivilization/detail/2411

អាំង ជូលាន

២០០០, *មនុស្ស និងដី*, រៃយំ, ភ្នំពេញ

អាំង ជូលាន, គង់ វីរៈ, រស់ សុខុម

២០០៧, "ពូនភ្នំស្រូវនៅតំបន់ភ្នំបូក, អង្គរ", *ខ្មែរ*, លេខ៨, ទំ.២៩៣-៣០៥,

Friends of Khmer Culture, ភ្នំពេញ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត